# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក

# Cambodia and the World Trade Organization



381
CHA
sh: Economi

បទឧទ្ទេសនាមរបស់ ឯកឧត្តម ចម ប្រសិទ្ធ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

និងជាប្រធានក្រុមចរចាកម្ពុជាក្នុងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

By H.E. Cham Prasidh

Senior Minister, Minister of Commerce

and Chief Negotiator of Cambodia's Accession to WTO

ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០០៤

Phnom Penh, July 2004

EIC ECONOMIC INSTITUTE OF CAMBODIA

library.ncdd.gov.kh
013879

**Cambodia and the World Trade Organization**

By
H.E. Cham Prasidh
Senior Minister, Minister of Commerce
and
Chief Negotiator of Cambodia's Accession to WTO

The World Trade Organization is, along with the World Bank and the International Monetary Fund, one of the three key international organizations governing the world economy. Until now, the WTO was the only one of the three-and indeed the only major international organization-that Cambodia had not joined. Now, that is about to change. On 11 September, 2003, WTO Ministers, meeting in Cancun, Mexico, invited Cambodia to become a member of WTO on terms spelled out in the Protocol of Accession that had been agreed between Cambodia and the WTO Members. This protocol is the result of detailed negotiations between Cambodia and members of WTO, which began in mid 1999, when Cambodia first submitted to WTO a description of its laws, regulations and policies governing international trade.Ratification of this Protocol will be one of the first issues that the new National Assembly will have to address when it meets. In accordance with WTO procedures, Cambodia will become a member of WTO thirty days after notifying WTO that the National Assembly has ratified the protocol.

What is contained in this Protocol? How will it affect Cambodia? What is the significance for Cambodia of joining WTO?

Before addressing these key questions, let me describe briefly the functions of the World Trade Organization and the process a non-member country must go through to become a member of WTO.

# កម្ពុជា និង អង្គការពាណិជ្ជកម្មពិភពលោក

បទឧទ្ទេសនាមរបស់

ឯកឧត្តម ចម ប្រសិទ្ធ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

និងជាប្រធានក្រុមចរចាកម្ពុជាក្នុងការសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក ធនាគារពិភពលោក និងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ជាអង្គការ អន្តរជាតិ បីសំខាន់ ដែលមានតួនាទីចាត់ចែងរៀបចំសេដ្ឋកិច្ចពិភពលោក ។ រហូតមកដល់ពេលនេះ ក្នុងចំណោមអង្គការទាំងបីមានតែអង្គការពាណិជ្ជកម្មពិភពលោកមួយប៉ុណ្ណោះដែលកម្ពុជាមិនទាន់បានចូលជាសមាជិក ។ នៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៃប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក លើកទី៥ ដែលបានប្រារព្ធធ្វើនៅទីក្រុង កាន់គូន ប្រទេសម៉ិចស៊ិច កាលពីថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣ កម្ពុជាត្រូវបានអនុញ្ញាតិអោយចូលជាសមាជិកនៃអង្គការដ៏សំខាន់នេះដោយផ្អែកតាមលក្ខខ័ណ្ឌ និងការសន្យាធ្វើ ដែលមានចែងក្នុងពិធីសារនៃការចូលជាសមាជិក ដែលបានព្រមព្រៀងរវាងកម្ពុជា និងសមាជិកដ៏ទៃទៀតនៃអង្គការនេះ ។ ពិធីសារនេះ គឺជាលទ្ធផលលំអិតនៃការចរចារវាងកម្ពុជា និង សមាជិក នានា ដែលចាប់ផ្តើមធ្វើជាលើកដំបូងកាលពីពាក់កណ្តាលឆ្នាំ ១៩៩៩ គឺនៅពេលដែលកម្ពុជាបានបញ្ជូនអនុស្សរណៈស្តីពីរបបពាណិជ្ជកម្មក្រៅប្រទេសរបស់ខ្លួនទៅអង្គការពាណិជ្ជកម្មពិភពលោក ។ ការផ្តល់សច្ចាប័នលើពិធីសារនេះ គឺជាបញ្ហាដំបូង និងសំខាន់បំផុត ដែលរដ្ឋសភាជាតិអណត្តិថ្មីត្រូវធ្វើនៅពេល ដែលរដ្ឋសភាជាតិអាចកោះប្រជុំបាន ។ កម្ពុជានឹងក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីបានជូនដំណឹងទៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកថាសភាជាតិបានផ្តល់សច្ចាប័នលើពិធីសារនេះរួចហើយ ។

- តើមានអ្វីខ្លះចែងក្នុងពិធីសារនេះ ?
- តើពិធីសារនេះ នឹងមានឥទ្ធិពលបែបណាមកលើប្រទេសកម្ពុជា ?
- តើអ្វីទៅជាសារៈសំខាន់ចំពោះកម្ពុជា ក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ?

## The WTO

The World Trade Organization has 147 members, including all major trading countries except Russia, which is in the final stages of accession. WTO members presently account for 96 percent of total world trade in goods and services. All of Cambodia's ASEAN partners are members of WTO, except for Laos and Vietnam, which are now in the accession process. In all 31 Least Developed Countries are members of the WTO.

**The World Trade Organization has three principal functions.**

The first of these is to establish and administer the international rules governing international trade in goods and services. These rules cover a wide range of issues relating directly to trade, or having an important bearing on trade. To give but a few examples, the rules specify how customs officials must value an imported good for purposes of applying an ad valorem tariff; how officials are to apply safety and health standards to imported products; what kinds of protection must be provided to intellectual property; and how free-trade arrangements among Members must be organized.

These rules are detailed and complex, and are contained in 25 formal agreements and understandings. The text of these legal requirements runs to some 300 pages.

# អង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក មានសមាជិកទាំងអស់ចំនួន ១៤៧ ប្រទេស ដែលរួមទាំងបណ្ដាប្រទេស ដែលមានកំលាំងសេដ្ឋកិច្ចធំបំផុតក្នុងពិភពលោក លើកលែងតែប្រទេសរុស្ស៊ី ។ បណ្ដាប្រទេសជាសមាជិកអាស៊ានទាំងអស់ សុទ្ធតែជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកលើកលែងតែ សាធារណៈរដ្ឋប្រជាមានិត ប្រជាធិបតេយ្យឡាវ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ។

## អង្គការពាណិជ្ជកម្មពិភពលោកមានតួនាទីសំខាន់បី

តួនាទី ទី១គឺបង្កើតអោយមានវិធានពាណិជ្ជកម្ម សំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិនៃពាណិជ្ជកម្មលើទំនិញនិង ពាណិជ្ជកម្មលើសេវាកម្ម ។ វិធាននេះបានបញ្ចូលនូវបញ្ហាជាច្រើនដែលទាក់ទងទៅនឹងការធ្វើពាណិជ្ជកម្ម រឺបញ្ហាដែលមានឥទ្ធិពលជាជុំកំភួនដល់ការធ្វើពាណិជ្ជកម្ម ។ ឧទាហរណ៍ វិធានខ្លះបានកំណត់យ៉ាងច្បាស់លាស់អំពីរបៀបវាយតំលៃលើទំនិញនាំចូល ដែលត្រូវអនុវត្តដោយមន្ត្រីគយ ដើម្បីឈានដល់ការយកពន្ធលើការនាំចូល រឺ វិធានដែលកំណត់ អំពីរបៀប ដែលត្រូវអនុវត្តលើស្តង់ដាសុវត្ថិភាព និង លទ្ធភាពប៉ះពាល់ដល់សុខភាពនៃទំនិញនាំចូល ការផ្តល់ការការពារចំពោះកម្មសិទ្ធបញ្ញា និងពីរបៀបរៀបចំធ្វើពាណិជ្ជកម្មសេរីរបៀបណា។

វិធានទាំងនេះមានលក្ខណៈលំអិត និងស្មុគស្មាញ ហើយត្រូវបានចែងនៅក្នុងកិច្ចព្រមព្រៀងចំនួន ១៨ ដែលមានជាង ៣០០ទំព័រ ។

The second function is to provide a means for resolving disagreements between trading countries with regard to the rules. Given their complexity, it is natural that there should sometimes be disagreement on the way the rules are to be applied in particular circumstances. The WTO dispute settlement mechanism provides countries with a way of resolving these disagreements, including, when all else fails, recourse to an independent dispute settlement panel that will make a ruling on the dispute. This mechanism is particularly important to small trading countries such as Cambodia. This is because it allows their disputes with larger trading countries to be settled on the basis of rules and the findings of objective outside experts, rather than being simply the outcome of negotiations between two countries of very unequal economic and trading power.

The third principal function of WTO is to serve as a forum for the progressive liberalization of international trade. This has occurred through a series of "Rounds", during which the members of WTO have negotiated tariff reductions on their imports of goods, and, in the Uruguay Round, have negotiated market access for each other's suppliers of services.

There is no official description of what a country has to do in order to join WTO. The Agreement establishing the WTO states simply that a country that is not a member may become a member "on terms to be agreed between it and the WTO." Nonetheless, certain practices have evolved over time that provide reasonable guidance as

តួនាទី ទី២ គឺផ្តល់នូវមធ្យោបាយសំរាប់ដោះស្រាយជំលោះពាណិជ្ជកម្ម រវាងប្រទេសជាសមាជិក ដែលកើត ចេញពីការមិនគោរពកិច្ចព្រមព្រៀង ។ ដោយសារភាពស្មុគស្មាញនៃកិច្ចព្រមព្រៀង ពេលខ្លះមានការមិនឯកភាពគ្នា លើការបកស្រាយវិធាននានា រវាងប្រទេសជាសមាជិក។ យន្តការដោះស្រាយជំលោះ នៃអង្គការពាណិជ្ជកម្មពិភពលោក ផ្តល់នូវរបៀបដោះស្រាយ ជំលោះដល់សមាជិកនានា ក្នុងករណីដែលមធ្យោបាយផ្សេងៗទៀតមិនអាចទទួលយកបាន ពីភាគីជម្លោះ ហើយក្រុមឯកទេសដោះស្រាយជំលោះ នឹងកំណត់យកវិធានមួយសំរាប់ ដោះស្រាយ ។ យន្តការនេះមានសារៈសំខាន់បំផុត ជាពិសេសសំរាប់ប្រទេសតូចតាច ដូចជា ប្រទេសកម្ពុជា ។ នោះគឺដោយសារយន្តការដោះស្រាយជំលោះនេះបង្កលក្ខណៈអោយជំលោះ ពាណិជ្ជកម្មទ្វេភាគីជាមួយប្រទេសធំ ត្រូវបានដោះស្រាយដោយផ្អែកលើវិធានច្បាប់ជាមូលដ្ឋាន ជាជាងដោះស្រាយដោយផ្អែក តែលើការចរចាជាមួយប្រទេស ដែលមានឥទ្ធិពលសេដ្ឋកិច្ច និងពាណិជ្ជកម្មធំជាង ។

តួនាទី ទី៣ របស់អង្គការពាណិជ្ជកម្មពិភពលោក គឺត្រូវបានប្រើជាវេទិកាសំរាប់ការចរចា ដើម្បីធ្វើអោយរីកចំរើនដល់ការធ្វើសេរីភាវូបនីយកម្ម នៃពាណិជ្ជកម្មអន្តរជាតិ ។ ការចរចា ត្រូវបានប្រព្រឹត្តទៅតាមរយៈវេទិកាចរចានានា ដែលសមាជិកទាំងអស់ចរចាកាត់បន្ថយពន្ធ នាំចូលផលិតផលទំនិញ ហើយចំពោះការចរចាបើកទីផ្សារលើវិស័យសេវាកម្ម ត្រូវបានប្រព្រឹត្ត ទៅនៅឯកិច្ចចរចា Uruguay round ។

ពុំមានសេចក្តីចែងជាផ្លូវការអំពីលក្ខខណ្ឌតំរូវនានា ដែលប្រទេសមួយត្រូវធ្វើ ដើម្បីបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទេ។ នៅក្នុងកិច្ចព្រមព្រៀងបង្កើត អង្គការពាណិជ្ជកម្មពិភពលោកគ្រាន់តែចែងយ៉ាងធម្មតាថា ប្រទេសមិនមែនជាសមាជិកមួយ អាចក្លាយជាសមាជិកបានដោយផ្អែកលើលក្ខខណ្ឌ ដែលនឹងត្រូវព្រមព្រៀងរវាងប្រទេសនោះ ជាមួយសមាជិកដទៃទៀតនៃអង្គការពាណិជ្ជកម្មពិភពលោក ។ ទោះបីយ៉ាងណាក៏ដោយការ

regards what an acceding country will have to do. Basically, a country seeking to join WTO must take on commitments in four areas related to the functions spelled out above:

- It must negotiate with members a set of "bindings" or maximum levels of tariffs that it will apply on its imports of goods;
- It must negotiate with members conditions for access by foreign services supplies to its services market;
- It must agree to limitations on those forms of support to agriculture that have an effect on international trade;
- It must bring its laws and regulations governing international trade into conformity with WTO rules before it joins WTO.

It should be noted, however, that the Members of WTO have agreed that when the country seeking to join WTO is a Least Developed Country, flexibility should be shown in all of the above four areas. In a decision taken by the General Council in December 2002, Members agreed that they would be bound by certain restraints in dealing with LDCs seeking to join WTO. In particular, they agreed that they would :

អនុវត្តន៍ជាក់ស្តែងមួយចំនួនក្នុងពេលកន្លងមកបានផ្តល់នូវគំរូសមស្របមួយ ចំពោះអ្វីដែលប្រទេសសុំចូលជាសមាជិកត្រូវធ្វើ ។ ជាទូទៅ ប្រទេសសុំចូលជាសមាជិកត្រូវធ្វើការសន្យាធ្វើលើវិស័យមួយចំនួនទាក់ទងទៅនឹងតួនាទីខាងលើគឺៈ

- ត្រូវចរចាជាមួយប្រទេសជាសមាជិកនានាដើម្បី ចងអត្រាពន្ធលើទំនិញនាំចូល រឺកំណត់អត្រាពន្ធខ្ពស់បំផុត ដែលត្រូវអនុវត្តលើទំនិញនាំចូល ។
- ត្រូវចរចាជាមួយប្រទេសជាសមាជិកនានា លើលក្ខខណ្ឌនៃការបើកទីផ្សារវិស័យសេវាកម្ម ដែលអនុញ្ញាតអោយអ្នកផ្តល់សេវាបរទេសមកផ្តល់សេវាកម្មលើទីផ្សារក្នុងស្រុករបស់ខ្លួន ។
- ត្រូវព្រមព្រៀងលើកំរិតនៃការឧបត្ថម្ភធនរបស់រដ្ឋ ចំពោះវិស័យកសិកម្មដែលមានឥទ្ធិពលដល់ពាណិជ្ជកម្មអន្តរជាតិ ។
- ត្រូវធ្វើយ៉ាងណាអោយច្បាប់ និងបទប្បញ្ញត្តិនានា ដែលគ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិស្របជាមួយ នឹង វិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកនៅមុនពេលចូលជាសមាជិក ។

ទោះបីយ៉ាងណាក៏ដោយ ជាការកត់សំគាល់គឺ ប្រទេសជាសមាជិកនានាបានផ្តល់នូវការអនុគ្រោះដែលអាចទទួលយកបានដោយប្រទេសក្រីក្រ ដែលសុំចូលជាសមាជិកលើវិស័យទាំងបួននេះ ។ នៅក្នុងសេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សា នៃអង្គការពាណិជ្ជកម្មពិភពលោក ដែលបានធ្វើកាលពីខែ ធ្នូ ឆ្នាំ ២០០២ បញ្ជាក់ថា ប្រទេសជាសមាជិកបានព្រមព្រៀងគោរពតាមលក្ខខ័ណ្ឌកំរិតមួយចំនួនក្នុងការចរចាជាមួយប្រទេសក្រីក្រដែលស្វែងសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ជាពិសេស សមាជិកនានាបានព្រមព្រៀងថាៈ

1) exercise restraint in seeking concession and commitments on trade in goods and services, taking into account the level of concessions and commitments undertaken by existing LDC Members of WTO; and 2) would allow an LDC to join WTO before all its laws and regulations were in full compliance with WTO rules, provided that the LDC presented a detailed workplan for achieving compliance in the years immediately following accession, and committed itself to executing fully that program.

Because Cambodia is a Least Developed Country, we expected to benefit from the flexibility established by this decision..

## Cambodia's Approach to the Accession Negotiations

### Trade, development and employment

Cambodia's strategy for promoting growth, development and poverty reduction has many elements, and these have been spelled out in our Poverty Reduction Strategy Paper and in the articulation of out Millenium Development Goals. Within this context, we understand that international trade can play a pivotal role, and that Cambodia will greatly benefit from following a trade-centered approach to development. From the outset, Cambodia recognized that joining WTO could significantly advance such a trade-centered approach. To achieve this outcome, however, we needed a negotiating strategy that would help us sort out the enormous detail and complexity of WTO rules and practices, and keep us focussed on those WTO accession issues that were critical for us. In formulating such a negotiating strategy, we started with the fundamental realities of present day Cambodia.

១- នឹងមិនតំរូវអោយប្រទេសក្រីក្រកាត់បន្ថយពន្ធនាំចូលជាគំហុគទេ ហើយតំរូវអោយធ្វើសម្បទានបើកទីផ្សារលើវិស័យមួយចំនួនប៉ុណ្ណោះ គឺពាណិជ្ជកម្មលើទំនិញ ពាណិជ្ជកម្មលើសេវាកម្ម

២- អនុញ្ញាត្តិអោយប្រទេសក្រីក្របានចូលជាសមាជិក មុនពេលដែលច្បាប់ និងបទប្បញ្ញតិទាំងឡាយរបស់គេ ស្របទាំងស្រុងទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ដោយផ្អែកតែទៅលើផែនការដែលបានដាក់ស្នើ ក្នុងការធ្វើអោយច្បាប់បញ្ញតិរបស់ខ្លួនស្របទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ក្នុងរយៈពេលមួយច្បាស់លាស់បន្ទាប់ពីថ្ងៃបានចូលជាសមាជិក ហើយប្តេជ្ញាបំពេញអោយបានជោគជ័យនូវផែនការនោះ ប៉ុណ្ណោះ ។

ដោយសារកម្ពុជាជាប្រទេសក្រីក្រ យើងសង្ឃឹមថា កម្ពុជាអាចទទួលបានផលប្រយោជន៍ពីការអនុគ្រោះ ដែលមាននៅក្នុងសេចក្តីសំរេចនេះ ។

## របៀបចរចាចូលជាសមាជិក របស់កម្ពុជា

### <u>ពាណិជ្ជកម្ម ការអភិវឌ្ឍន៍ និងការបង្កើតការងារធ្វើ</u>

ចាប់តាំងពីដំបូងមកកម្ពុជាយល់ឃើញថា ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនឹងមាននាទីយ៉ាងសំខាន់ ក្នុងការបង្កើតល្បឿនអភិវឌ្ឍន៍របស់ខ្លួន ។ ដើម្បីទាញយកប្រយោជន៍អោយបានច្រើនបំផុត និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានអោយនៅទាបបំផុត កម្ពុជាត្រូវរៀបចំយុទ្ធសាស្ត្រ នៃការចរចាមួយ ដែលសមស្របបំផុតសំរាប់ប្រយោជន៍កម្ពុជា ដែលយុទ្ធសាស្ត្រនេះនឹងផ្តល់នូវលទ្ធផល ដែលកម្ពុជាចង់បាន ។ ក្នុងការបង្កើតយុទ្ធសាស្ត្រនេះឡើង យើងបានចាប់ផ្តើមពីមូលដ្ឋានជាក់ស្តែង នៃស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា ។

Cambodia is a small country with a relatively small population, a large proportion of which is impoverished. At the same time, Cambodia's population has been growing rapidly. The number of young people entering the job market has thus been growing, and will continue to grow at a rapid pace in the years ahead. Expanding rapidly employment opportunities is thus a major challenge facing Cambodia. Given the lack of purchasing power in the domestic economy, a rapid creation of new jobs can only result from producing for other, larger markets. In other words, Cambodia's future growth and development must be outward oriented, with exports playing a key role in creating employment and reducing poverty.

Cambodia's experience with its garment industry illustrates the role that exports can play in increasing employment rapidly and helping to alleviate poverty. Our garment industry now employs directly some 240,000 people. Moreover, more than half of these jobs has been created during the past 5 years, making the industry by far the largest source of jobs growth during that period. The workers concerned are generally from low-income families, and their earnings usually flow back to these families in the countryside.

A second reality of Cambodia's present situation is that the necessary increase in exports and employment can occur only if there is a rapid expansion of investment. Because adequate savings, skills and technology are not always available within Cambodia, foreign investment has an important role to play in bringing about the necessary expansion. Foreign direct investment has an especially critical role to play in expanding exports, since foreign firms know best foreign markets, and possess the technology, managerial experience and marketing channels that are needed to engage successfully in exporting.

កម្ពុជាជាប្រទេសតូច មានប្រជាជនតិច ប្រជាជនមួយភាគធំជាជនក្រីក្រ និងមាន កំណើនប្រជាជនខ្ពស់ ។ ចំនួនយុវជនដែលត្រូវការការងារធ្វើមានកំណើនខ្ពស់ ហើយកំណើននេះ នឹងកើនឡើងថែមទៀតយ៉ាងឆាប់រហ័សក្នុងបណ្តាឆ្នាំខាងមុខ ។ ដូច្នេះការបង្កើតការងារថ្មីៗ ថែមទៀតអោយបានឆាប់ គឺជាបញ្ហាប្រឈម ដែលកម្ពុជាកំពុងជួបប្រទះ ។ ដោយសារកំលាំង ទិញនៅក្នុងស្រុកមានកំរិតទាបពេក ការបង្កើតការងារថ្មីៗទៀតគឺអាស្រ័យ តែលើការផលិត សំរាប់ផ្គត់ផ្គង់លើទីផ្សារធំៗ នៅបរទេសតែប៉ុណ្ណោះ ។ ដូច្នេះកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ របស់កម្ពុជានៅពេលអនាគត គឺជាការអភិវឌ្ឍន៍ពីក្នុងទៅក្រៅ ដែលការនាំចេញមាននាទីយ៉ាង សំខាន់ក្នុងការបង្កើតការងារថ្មី និងកាត់បន្ថយភាពក្រីក្រ ។

បទពិសោធន៍របស់កម្ពុជា លើឧស្សាហកម្មកាត់ដេរសំលៀកបំពាក់បានបង្ហាញច្បាស់ពី តួនាទីនៃការនាំចេញក្នុងការបង្កើតការងារថ្មីយ៉ាងឆាប់រហ័យ និងការកាត់បន្ថយភាពក្រីក្រ ។ បច្ចុប្បន្នឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ស្រូបយកកំលាំងពលកម្មចំនួនប្រមាណ ២៤០ ០០០ នាក់ ហើយដែលចំនួនពាក់កណ្តាលនៃចំនួនការងារនេះត្រូវបានបង្កើតឡើងក្នុងរយៈពេល៥ឆ្នាំ ចុងក្រោយនេះ ដែលយើងអាចចាត់ទុកថាឧស្សាហកម្មកាត់ដេរគឺជាប្រភពផ្តល់ការងារធំជាងគេ តែមួយគត់ក្នុងរយៈពេលនេះ ។ កម្មករភាគច្រើនមានប្រភពចេញពីគ្រួសារ ដែលមានប្រាក់ ចំណូលទាប ហើយប្រាក់ចំណូលរបស់ពួកគេជាធម្មតាផ្គត់ផ្គង់ទៅអោយគ្រួសារ នៅឯជនបទ ។

ស្ថានភាពជាក់ស្តែងទី២ នៅកម្ពុជាបច្ចុប្បន្នៈ គឺថាការបង្កើនបរិមាណទំនិញនាំចេញ និងការបង្កើតការងារថ្មី អាចកើតមានឡើងបាន លុះត្រាតែមានកំណើនរហ័សនៃការធ្វើវិនិយោគ ពីបរទេស ។ ពីព្រោះសព្ទ័យធន បច្ចេកទេសជំនាញ និងបច្ចេកវិទ្យា ពេលខ្លះមិនអាចរកបានទេ នៅកម្ពុជា ហើយក្រុមហ៊ុនវិនិយោគបរទេស មាននាទីយ៉ាងសំខាន់ក្នុងការពង្រីកវិស័យនាំចេញ ដោយហេតុថា ក្រុមហ៊ុនបរទេសដឹងពីទីផ្សារសំរាប់នាំចេញ មានបច្ចេកវិទ្យា បទពិសោធន៍ នៃការគ្រប់គ្រង បណ្តាញម៉ាខេទិញ ដែលជាកត្តាធ្វើអោយការរកស៊ីទទួលបានប្រាក់ចំណេញ ។

Again, Cambodia's experience with its garment industry provides a concrete illustration of the way in which foreign direct investment can be used to expand exports rapidly. Garment exports rose from $26 million in 1995 to $650 million in 1999 and more than $1.3 billion in 2003. The knowledge by foreign investing firms of marketing and other requirements in foreign markets has obviously been a key element in allowing this rapid expansion of exports.

This emphasis on exports and foreign direct investment must not, however, imply any neglect of the important role of micro, small and medium sized enterprises in Cambodia's development. These enterprises produce almost exclusively for the domestic market, and are an important breeding ground for the development of indigenous entrepreneurship. Their role is especially important in rural areas, where they are a major source of employment and employment growth, based on adding value to agricultural production, fisheries, handicrafts, and small manufacturing.

The third fundamental reality of Cambodia is that it is a rural society and economy, with most Cambodians depending directly or indirectly on agriculture for their livelihood. Cambodia is competitive or potentially competitive across a fairly wide range of agricultural sectors. Much remains to be done, however, to realize the full potential of this competitiveness and prospective competitiveness. Achieving this will require, among other things, very large investments in rural infrastructure, in agricultural extension services to improve producer skills, and improved processing of food products, for example the milling and grading of rice to international standards. Here, Government programs, the donor community and foreign direct investment all have an important role to play. The development of Cambodia's agriculture

បទពិសោធន៍លើឧស្សាហកម្មកាត់ដេរសំលៀកបំពាក់របស់កម្ពុជា បានបង្ហាញច្បាស់ពីរបៀបដែលការវិនិយោគផ្ទាល់ពីបរទេស អាចត្រូវបានប្រើប្រាស់ក្នុងការពង្រីកការនាំចេញ ។ ការនាំចេញសំលៀកបំពាក់បានកើនឡើងពី ២៦ លានដុល្លា ក្នុងឆ្នាំ ១៩៩៥ ទៅ ៦៥០ លានដុល្លា នៅឆ្នាំ ១៩៩៩ និងច្រើនជាង ១ ៣០០ លានដុល្លា ក្នុងឆ្នាំ ២០០៣ ។ ចំណេះដឹងរបស់សហគ្រាសវិនិយោគបរទេសអំពីទីផ្សារ និងតំរូវការចាំបាច់របស់ទីផ្សារក្រៅប្រទេស គឺជាកត្តាយ៉ាងសំខាន់ក្នុងការពង្រីកការនាំចេញនេះ ។

ទោះបីជាយ៉ាងណាក៏ដោយ ទស្សនៈខាងលើ អំពីការនាំចេញ និង ការវិនិយោគផ្ទាល់ពីបរទេស មិនត្រូវមិនគិតដល់នាទីសំខាន់របស់សហគ្រាសធុនតូច និងធុនមធ្យមក្នុងការអភិវឌ្ឍន៍នៅកម្ពុជាដែរ ។ សហគ្រាសទាំងនេះផលិត ហើយផ្គត់ផ្គង់ទីផ្សារក្នុងស្រុក ហើយក៏រួមចំណែកក្នុងការផ្តល់ការងារធ្វើនៅកម្ពុជា ទោះបីមានកំណើនទាបក៏ដោយ ហើយក៏ជាមូលដ្ឋានសំខាន់ក្នុងការបង្កើតអោយមានសហគ្រិនល្អនៅកម្ពុជា ។

ស្ថានភាពជាក់ស្តែងជាមូលដ្ឋានទី៣នៅកម្ពុជាគឺ សង្គមជនបទ និងសេដ្ឋកិច្ច ដែលប្រជាជនភាគច្រើន ពឹងពាក់ដោយផ្ទាល់រឺប្រយោលលើវិស័យកសិកម្ម ។ កម្ពុជាជាប្រទេសដែលមានសក្តានុពលក្នុងការប្រកួតប្រជែងក្នុងវិស័យកសិកម្ម ប៉ុន្តែនៅមានការងារជាច្រើនទៀត ត្រូវធ្វើដើម្បីអោយគេអាចមើលឃើញនូវសក្តានុពល នៃការប្រកួតប្រជែងនេះ ។ ដើម្បីសំរេចបានដូចនេះ តំរូវអោយមានការធ្វើវិនិយោគច្រើនថែមទៀតលើការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងវិស័យកសិកម្ម បង្កើនជំនាញក្នុងការផលិត និងជំរុញការកែច្នៃម្ហូបអាហារដូចជា ម៉ាស៊ីនកិនស្រូវ និងការលើកកំពស់គុណភាពអង្ករអោយឆ្លើយតបបានទៅនឹងស្តង់ដារអន្តរជាតិ ។ ដូច្នេះនៅទីនេះ កម្មវិធីរបស់រដ្ឋាភិបាល សហគមន៍អ្នកផ្តល់ជំនួយ និងការធ្វើវិនិយោគពីបរទេស មាននាទីយ៉ាងសំខាន់ក្នុងការបំពេញការងារនេះអោយបានជោគជ័យ ។ ការអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា គឺជាដំណើរវែងឆ្ងាយ និង ស្មុគ្រស្មាញមួយ ដែលតំរូវអោយមានការគាំទ្រពី

will be a long and complex process that needs to be backstopped by a trade policy that provides reasonable protection to domestic producers from agricultural imports, while ensuring that Cambodian agriculture that is competitive has access to markets abroad.

In addition to these fundamental realities regarding Cambodia's own situation, an important reality of the international trading regime needs to be mentioned. In accordance with the WTO Agreement on Textiles and Clothing, the special regime governing trade in garments comes to an end on 1 January 2005. This regime allowed countries to apply quantitative restrictions on imports of clothing. Accordingly, the garment exports of almost all countries have been subject to quotas in major world markets, in particular the United States. Cambodia's garment exports have also been subject to quotas. On 1 January 2005, however, WTO members are obliged to eliminate quotas on clothing imports from other WTO members. As of that date, access to world markets will be unrestrained for WTO members. If Cambodia is not a member on that date, countries will be free to continue to impose quotas on Cambodia's exports, and will undoubtedly do so. Thus, failure to join WTO by 1 January 2005 would put Cambodia's garment industry at a significant disadvantage relative to its competitors.

**Formulating an Accession Strategy**

The considerations outlined above allowed the WTO negotiating team to formulate some broad guidelines for our negotiations with WTO

នយោបាយពាណិជ្ជកម្ម ដែលផ្ដល់ការការពារសមស្របដល់ កសិករនិងផលិតករក្នុងស្រុក ពីការនាំចូលផលិតផលកសិកម្ម ហើយធានាអោយបានថា ផលិតផលកសិកម្មរបស់កម្ពុជាអាច ប្រកួតប្រជែងបាននៅលើទីផ្សារក្រៅប្រទេស ។

ក្រៅពីស្ថានភាពជាក់ស្ដែងជាមូលដ្ឋានខាងលើស្ថានភាពជាក់ស្ដែង នៃរបបពាណិជ្ជកម្ម ក្រៅប្រទេសរបស់កម្ពុជាក៏គួរតែលើកយកមកពិភាក្សាផងដែរ ។ ដោយយោងទៅលើកិច្ច ព្រមព្រៀងរបស់អង្គការ ពាណិជ្ជកម្មពិភពលោក ស្ដីអំពីវាយនភ័ណ្ឌ និងសំលៀកបំពាក់ វិធានពិសេសសំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម សំលៀកបំពាក់ នឹងត្រូវផុតរលត់នៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥ ខាងមុខនេះ ។ វិធាននេះអនុញ្ញាតអោយប្រទេសជាសមាជិកអនុវត្តការ ដាក់កំហិតលើបរិមាណនាំចូលផលិតផលសំលៀកបំពាក់ នៅក្នុងទីផ្សាររបស់ខ្លួន ។ ដូច្នេះ ហើយការនាំចេញសំលៀកបំពាក់ពីបណ្ដាប្រទេសជាសមាជិកស្ទើរតែទាំងអស់ទៅកាន់ទីផ្សារ ធំៗ ជាពិសេសសហរដ្ឋអាមេរិក ត្រូវជាប់កូតា ។ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥ តទៅ ប្រទេសជាសមាជិកទាំងអស់ត្រូវលុបបំបាត់ការដាក់កូតានាំចូលសំលៀកបំពាក់ពីបណ្ដាប្រទេស ជាសមាជិកនានា ។ ចាប់ពីថ្ងៃនោះតទៅ ការនាំចេញផលិតផលសំលៀកបំពាក់ទៅទីផ្សារ ពិភពលោកនឹងគ្មានការដាក់កំហិតទៀតទេ ចំពោះប្រទេសជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោកទាំងអស់ ។ ប្រសិនបើកម្ពុជា មិនអាចចូលជាសមាជិកបាននៅថ្ងៃនោះ បណ្ដា ប្រទេសនានា នឹងនៅតែបន្តដាក់កូតាលើការនាំចេញសំលៀកបំពាក់ពីកម្ពុជា ។ ដូច្នេះ បើកម្ពុជា មិនអាចចូលជាសមាជិកអង្គការ ពាណិជ្ជកម្មពិភពលោក នៅត្រឹមថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៥ ទេនោះនឹងបណ្ដាលអោយឧស្សាហកម្មកាត់ដេរសំលៀកបំពាក់កម្ពុជាបាត់លទ្ធភាពប្រកួត ប្រជែងរបស់ខ្លួន ។

## ការបង្កើតយុទ្ធសាស្ត្រ នៃការចរចាចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក

ដោយយកចិត្តទុកដាក់ពិចារណាលើចំណុចទាំងអស់ខាងលើ អនុញ្ញាតអោយក្រុម អ្នកចរចារបស់យើង បង្កើតបាននូវគោលការណ៍ណែនាំទូលំទូលាយសំរាប់ការចរចាជាមួយ

members. These guidelines were designed to ensure that our negotiating strategy at WTO was fully consistent with our view of the important role that international trade is playing, and can continue to play, in Cambodia's economic development. The six main building blocks around which our strategy was constructed were as follows.

1. **Timing.** We targeted a rapid accession to WTO. The need for a rapid accession was driven mainly by the 1 January 2005 deadline facing our garment industry, as explained above. But we also believed that it was in Cambodia's interests to achieve quickly the assured access to all export markets that is guaranteed by WTO membership. Moreover, we believed that the decision by the WTO General Council on the accession of Least Developed Countries, described above, made a rapid accession feasible. We understood that we would need to draft and adopt a large number of laws so as to create a trade regime that was consistent with WTO rules. But we also knew that the decision by the General Council would allow us to do part of this after accession. Further, Cambodia had not developed any domestic industries that were dependent for their survival on high tariff protection. Allowing time for domestic industry to adjust to any tariff reductions that might be required by accession was thus not a consideration.

សមាជិកនានា នៃអង្គការពាណិជ្ជកម្មពិភពលោក ។ គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើងសំដៅធានាថា យុទ្ធសាស្ត្រនៃការចរចាររបស់យើងនៅអង្គការពាណិជ្ជកម្មពិភពលោកស្របគ្នាទាំងស្រុងទៅនឹងទស្សនៈនៃតួនាទីដ៏សំខាន់របស់ពាណិជ្ជកម្មអន្តរជាតិ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ។ ចំណុចសំខាន់ទាំង៦ នៃយុទ្ធសាស្ត្ររបស់យើងគឺ :

១- **<u>ពេលវេលា</u>** : យើងដាក់ផែនការចរចាររហ័ស ដើម្បីបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ភាពចាំបាច់ក្នុងការចូលជាសមាជិកអោយបានរហ័ស គឺត្រូវបានជំរុញដោយការកំណត់ពេលត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥ ដែលជាពេលវេលាដែលបណ្តាលអោយឧស្សាហកម្មកាត់ដេរសំលៀកបំពាក់មានផលប៉ះពាល់ដូចបានពន្យល់រួចហើយពីខាងដើម ។ ប៉ុន្តែយើងក៏មានជំនឿផងដែរលើផលប្រយោជន៍របស់កម្ពុជាក្នុងការធានាដល់ការបើកទីផ្សារសំរាប់នាំចេញអោយបានរហ័យ តាមរយៈសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ច្រើនជាងនេះទៅទៀត យើងមានជំនឿថា សេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សានៃអង្គការពាណិជ្ជកម្មពិភពលោក អំពីការចរចាចូលជាសមាជិករបស់បណ្តាប្រទេសក្រីក្រ ដូចដែលបានរៀបរាប់ជូនខាងដើមស្រាប់អាចធ្វើអោយគោលដៅនៃការចរចាឆាប់រហ័សរបស់កម្ពុជាប្រព្រឹត្តទៅបាន ។ យើងយល់ថា យើងត្រូវការធ្វើសេចក្តីព្រាង និង អនុម័តនូវច្បាប់មួយចំនួនធំ ដើម្បីបង្កើតអោយមានរបបពាណិជ្ជកម្មមួយស្របជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ ប៉ុន្តែយើងក៏យល់ដែរថា សេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សានឹងអនុញ្ញាតអោយយើងមានពេលវេលាសំរាប់ធ្វើផ្នែកខ្លះ ដែលនៅសេសសល់បន្ទាប់ពីការបានចូលជាសមាជិក ។ ម្យ៉ាងទៀតកម្ពុជាមិនបានបង្កើតអោយមានឧស្សាហកម្មក្នុងស្រុក ដែលតំរូវអោយមានការការពារពីការយកពន្ធខ្ពស់លើផលិតផលនាំចូលដើម្បីអោយឧស្សាហកម្មក្នុងស្រុកនោះអាចប្រកួតប្រជែងបាននោះទេ ។ ដូច្នេះការតំរូវអោយមានពេលវេលាគ្រប់គ្រាន់ ដើម្បីអោយឧស្សាហកម្មក្នុងស្រុកសំរបសំរួលបានបន្ទាប់ពីការកាត់បន្ថយពន្ធនាំចូល ដែលជាលទ្ធផលនៃការចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកនោះមិនមែនជាការណ៍មួយ ដែលត្រូវយកចិត្តទុកដាក់ពិចារណានោះទេ ។

In short, we saw a number of reasons for going forward rapidly, and no arguments in favor of a slower accession.

2. **Tariff concessions.** Shortly before negotiations with WTO began, Cambodia had undertaken a reform of its tariffs on imports of goods. This reform had reduced the number of tariff "bands" from 12 to 4, so that after the reform all goods were charged a duty of either 0, 7, 15, or 35 per cent. In the process, we eliminated some higher tariff rates that had previously been applied. We were persuaded that these reductions and simplifications had met our needs and also contributed to the over-all liberalization of world trade. We were also mindful of the need to keep some protection in place for our micro, small and medium sized enterprises and for agriculture. Finally, tariffs contributed an important part of our budget revenue. For all of these reasons, we were determined during the WTO negotiations to avoid any commitment to reduce tariffs further.

3. **Export orientation.** In order to be competitive on world markets, an export industry needs to have access to raw materials and intermediate inputs at world market prices. Cambodia has always recognized this, and, under the Law on Investment, has provided export industries with duty-free access to imported capital and intermediate goods, and raw materials. The way in which Cambodia does this, however, is not fully compatible with WTO rules.

ជាសង្ខេប យើងមានហេតុផលជាច្រើនក្នុងការបង្កើនល្បឿន នៃការចរចារចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ហើយគ្មានហេតុផលណាមួយក្នុងការពន្យាពេលនៃការចូលជាសមាជិកនោះទេ ។

**២-__ការធ្វើសមម្យទានពន្ធគយៈ__** នៅមុនពេលចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកចាប់ផ្តើមតែបន្តិចប៉ុណ្ណោះ កម្ពុជាបានកែទំរង់លើរបបពន្ធគយរបស់ខ្លួន ។ ការកែទំរង់នៅពេលនោះ បានកាត់បន្ថយក្រុមពន្ធគយពី ១២ ក្រុម ទៅ ៤ក្រុម ។ ដូច្នេះបន្ទាប់ពីការកែទំរង់ ទំនិញនាំចូលទាំងអស់ ជាប់ពន្ធត្រឹមអត្រា ០ភាគរយ ៧ភាគរយ ១៥ភាគរយ រឺ ៣៥ភាគរយ ។ ក្នុងដំណើរនៃការកែទំរង់ យើងបានលប់ចោលនូវអត្រាពន្ធខ្ពស់ជាងនេះ ដែលធ្លាប់បានអនុវត្តកន្លងមក ។ យើងមានជំនឿថា ការកាត់បន្ថយពន្ធនាំចូល និងធ្វើការសាមញ្ញកម្មបែបនេះ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់យើង ព្រមទាំងរួមវិភាគទានដល់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មនៃពិភពលោកនេះ ។ យើងក៏ដឹងផងដែរ អំពីសេចក្តីត្រូវការក្នុងការរក្សាទុកនូវការការពារខ្លះ ចំពោះសហគ្រាសធុនតូច និងធុនមធ្យមរបស់យើងពិសេសវិស័យកសិកម្ម ។ ម្យ៉ាងទៀត ពន្ធលើការនាំចូលជាចំណែកមួយយ៉ាងសំខាន់នៃចំណូលថវិកាជាតិ ។ ដោយហេតុផលទាំងអស់ខាងលើនេះ ហើយបានជាក្នុងរយៈពេលនៃការចរចាយើងបានសំរេចថា មិនធ្វើការសន្យាក្នុងការកាត់បន្ថយពន្ធនាំចូលបន្ថែមទៀតទេ ។

**៣-__ទិសដៅនៃការនាំចេញៈ__** ដើម្បីអាចប្រកួតប្រជែងបាននៅលើទីផ្សារពិភពលោកឧស្សាហកម្មនាំចេញ ត្រូវតែមានលទ្ធភាពក្នុងការរកទិញវត្ថុធាតុដើមផ្សេងៗតាមតំលៃទីផ្សារពិភពលោក។ កម្ពុជាជានិច្ចជាកាលបានទទួលស្គាល់នូវចំណុចដ៏សំខាន់នេះ ហើយតាមរយៈច្បាប់វិនិយោគមុនបានអនុញ្ញាតអោយឧស្សាហកម្មនាំចេញមានសិទ្ធិនាំចូលនូវទុនទំនិញពាក់កណ្តាលសំរេច និងវត្ថុធាតុដើមសំរាប់បំរើផលិតកម្មដោយមិនបង់ពន្ធ លើការនាំចូល ។ ប៉ុន្តែអ្វីដែលកម្ពុជាបានធ្វើនៅពេលនេះ គឺមិនស្របទៅនឹងវិធានរបស់អង្គការពាណិជ្ជកម្ម

Nevertheless, we understood that maintaining these privileges was essential to our garment industry, and to our future ability to attract other export oriented industries. We were thus determined to maintain our capacity to offer such advantages, despite WTO rules.

4. **Improving the investment climate and fostering foreign direct investment.** As mentioned earlier, increased exports and jobs will depend on increased investment, in particular foreign direct investment. We understood, therefore, the central importance of using our accession to WTO as a means to increase the attractiveness of Cambodia as a place to invest. WTO membership offers three main ways to do this.

**First,** WTO membership provides certain assurances for investors wishing to produce in Cambodia for export to other markets. This is because a Cambodian exporter can be certain that his goods will be charged a rate of duty in the importing country that is no higher than the rate charged by the importing country on identical or similar goods coming from other exporting countries. This is called Most Favored Nation Treatment. Moreover, because most WTO members have "bound" (i.e. set legal ceilings on) most of their tariff lines, a Cambodian exporter will know the maximum legal duty that can be charged on his export good in any WTO member country. Further, a Cambodian exporter can be certain that his exports will not be subject to quotas or any kind of quantitative restraint in his export markets (for

ពិភពលោកទេ។ ទោះបីយ៉ាងណាក៏ដោយ យើងយល់ថាការរក្សាទុកនូវសិទ្ធិពិសេសនេះ គឺមានសារៈសំខាន់ចំពោះឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងលទ្ធភាពចំពោះនៃការទាក់ទាញវិនិយោគសំរាប់ការនាំចេញនាពេលអនាគតរបស់យើង ។ ដូច្នេះ យើងសំរេចរក្សាទុកសិទ្ធិក្នុងការផ្តល់សិទ្ធិពិសេសនេះ ទោះបីផ្ទុយជាមួយវិធានអង្គការពាណិជ្ជកម្មពិភពលោកក៏ដោយ ។

**៤-ធ្វើអោយបរិយាកាសវិនិយោគល្អប្រសើរ និងគាំទ្រការវិនិយោគផ្ទាល់ពីបរទេស:** ដូចបានជំរាបជូនខាងដើមរួចមកហើយ កំណើននៃការនាំចេញ និងកំណើននៃបង្កើតការងារថ្មី គឺអាស្រ័យទាំងស្រុងលើកំណើននៃការធ្វើវិនិយោគ ជាពិសេសការវិនិយោគផ្ទាល់ពីបរទេស ។ យើងបានដឹងពីចំណុចនេះ ដូច្នេះហើយ ចំណុចសំខាន់នៃការប្រើប្រាស់សមាជិកភាព របស់យើងក្នុងអង្គការពាណិជ្ជកម្មពិភពលោកគឺជាមធ្យោបាយមួយបង្កើនភាពទាក់ទាញ របស់កម្ពុជាឱ្យទៅជាកន្លែងសំរាប់ធ្វើវិនិយោគមួយ ។ សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោកផ្តល់នូវមធ្យោបាយបី ក្នុងការធ្វើបែបនេះ :

**ទីមួយ:** សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោកផ្តល់ការធានាជាក់លាក់មួយចំពោះអ្នកវិនិយោគ ដែលមានបំណងធ្វើផលិតកម្មនៅកម្ពុជា ដើម្បីនាំចេញទៅកាន់ទីផ្សារនានានៃពិភពលោក ។ នោះគឺដោយសារអ្នកនាំចេញជឿជាក់ថា ទំនិញនាំចេញរបស់ខ្លួនត្រូវជាប់ពន្ធក្នុងប្រទេសនាំចូលក្នុងអត្រាមិនខ្ពស់ជាងទំនិញដូចគ្នា រឺស្រដៀងគ្នា ដែលនាំចូលពីប្រទេសផ្សេងៗទៀត ។ គោលការណ៍នេះ ហៅថាគោលការណ៍ស្មើភាពនៃប្រជាជាតិទទួលបានការអនុគ្រោះបំផុត។ ក្រៅពីនេះ ដោយសារប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកភាគច្រើន បានចងអត្រាពន្ធលើទំនិញនាំចូល អ្នកនាំទំនិញចេញពីកម្ពុជា អាចដឹងពីអត្រាពន្ធខ្ពស់បំផុតដែលត្រូវបង់លើទំនិញរបស់ខ្លួន នៅក្នុងបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ម្យ៉ាងទៀតអ្នកនាំចេញ ទំនិញពីកម្ពុជាអាចដឹងផងដែរថា ទំនិញរបស់ខ្លួនមិនជាប់កូតា រឺការដាក់កំហិតលើបរិមាណនាំចេញនៅលើទីផ្សារនាំចេញនោះទេ (ចំពោះផលិតផលសំលៀកបំពាក់ ត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៥) ។ ដោយសារហេតុផលទាំងអស់នេះហើយ សមាជិកភាពនៃអង្គការពាណិជ្ជកម្មពិភពលោកជួយកាត់បន្ថយភាព

garments, this will be true only after January 2005). For all of these reasons, WTO membership reduces the uncertainty facing an investor who wants to produce in Cambodia for export to other markets.

**Second,** WTO membership requires an intensified effort by Cambodia to put in place the legal framework required by business. The Royal Government has for some time been actively engaged in developing and submitting to the National Assembly the laws necessary for a modern, liberal, and business-friendly legal environment. A member of WTO must have laws that embody WTO rules concerning international trade and activities related to trade. We understood from the outset that this would be necessary, and welcomed the requirement as a way of ordering and accelerating our efforts to create a proper legal framework for business that fully reflects international norms.

**Third,** we understood from the outset that our attractiveness to investors depends on the availability of the infrastructure required by businesses. This infrastructure includes services such as telecommunications, transportation, banking, accounting and auditing. The investment environment is also enhanced by the availability of an educated and trained labor force. We saw the WTO accession negotiations on services as an opportunity to encourage foreign investment in key services infrastructure, and therefore as an opportunity to enhance our over-all environment for business. Likewise, foreign participation in adult education and training would help develop the skilled work force that is necessary to attract skill-based industries and to allow for increased wages.

មិនប្រាកដចំពោះវិនិយោគិន ដែលមានបំណងមកវិនិយោគនៅកម្ពុជាសំរាប់នាំចេញទៅទីផ្សារនៃបណ្តាប្រទេសនានា (ចំពោះវិនិយោគិន ដែលចង់នាំចេញទៅបណ្តាប្រទេសជាសមាជិកអាស៊ានត្រូវអនុវត្តតាមលក្ខខ័ណ្ឌរបស់អាស៊ាន) ។

**ទីពីរ:** សមាជិកភាពរបស់អង្គការពាណិជ្ជកម្មពិភពលោក តំរូវអោយកម្ពុជាបំពេញការងារជាច្រើន ក្នុងការបង្កើតអោយមាននូវក្របខ័ណ្ឌច្បាប់សំរាប់គ្រប់គ្រងពាណិជ្ជកម្មអោយបានគ្រប់គ្រាន់ ។ រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងការបង្កើត និងដាក់ជូនសភាជាតិនូវច្បាប់សំខាន់ៗ ដែលមានលក្ខណៈទំនើបសេរី និងត្រឹមត្រូវសំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម ។ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ប្រទេសមួយត្រូវតែមានច្បាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្មអន្តរជាតិស្របជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ។ កម្ពុជាយល់ស្របជាមួយនឹងលក្ខណៈបែបនេះ និងយល់ថាជាការចាំបាច់ ហើយបានស្វាគមន៍នូវតំរូវការទាំងឡាយ នឹងជំរុញអោយកម្ពុជាបង្កើនល្បឿនក្នុងការបង្កើតអោយមាននូវក្របខ័ណ្ឌច្បាប់មួយសំរាប់គ្រប់គ្រងការធ្វើពាណិជ្ជកម្ម ដែលស្របតាមស្តង់ដារអន្តរជាតិ ។

**ទីបី:** កម្ពុជាយល់ឃើញថា លក្ខណៈនៃការការទាក់ទាញវិនិយោគិនរបស់កម្ពុជាគឺអាស្រ័យលើភាពមានគ្រប់គ្រាន់នូវហេដ្ឋារចនាសម្ព័ន្ធសំរាប់ការធ្វើពាណិជ្ជកម្ម ។ ហេដ្ឋារចនាសម្ព័ន្ធនេះ រួមមានសេវាកម្មនានា ដូចជាទូរគមនាគមន៍ ការដឹកជញ្ជូន ធនាគារ គណនេយ្យកម្ម និង សវនកម្ម ។ បរិយាកាសនៃការវិនិយោគ ក៏អាចធ្វើអោយប្រសើរបានដែរ តាមរយៈការអប់រំ និងហ្វឹកហ្វឺនកំលាំងពលកម្ម ។ កម្ពុជាដឹងថា ការចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក លើការបើកទីផ្សារវិស័យសេវាកម្ម គឺជាឱកាសមួយ ដើម្បីលើកទឹកចិត្ត វិនិយោគិនផ្ទាល់ពីបរទេសអោយវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសេវាកម្មគន្លឹះ មួយចំនួនហើយក៏ជាឱកាសមួយដែលក្នុងការធ្វើអោយប្រសើរឡើងនូវបរិយាកាសចំពោះការធ្វើ ពាណិជ្ជកម្មជំនាញ ។ ដូចគ្នានេះដែរ ការវិនិយោគលើការអប់រំពីបរទេស និងហ្វឹកហ្វឺនមនុស្សពេញវ័យ នឹងជួយបង្កើនពលកម្ម ដែលចាំបាច់សំរាប់ទាក់ទាញឧស្សាហកម្មជំនាញ និងដើម្បីបង្កើនចំណូល ។

For these reasons, we understood that our negotiations on services could advance our over-all strategy of improving the business environment. We were aware that the decision of the WTO General Council (see above) called for members to limit the scope of negotiations on services. However, rather than seeking to limit our commitments to the bare minimum referred to by the General Council, we preferred to address services issues on a case-by-case basis, and when we were convinced that agreeing to liberalization in a particular services sector would help move us toward our broader development objectives, we were prepared to engage in negotiations and take on commitments.

5. **Retaining policy options and flexibility on agriculture.** Market access (point 1, above) and improvements in the investment environment (point 4, above) will benefit agriculture as well as manufacturing and services. We knew, however, that there were special rules in WTO regarding the way governments can support their agricultural sector. These rules are designed to insure that support measures that distort trade are not introduced or increased, and that any existing measures that distort trade are gradually reduced to minimal amounts. We believe that Cambodia is a competitive or potentially competitive agricultural producer across a broad range of agricultural products. Rules that reduce the support provided by other countries to their less efficient producers will therefore ultimately be to the benefit of Cambodia. As mentioned above, however, we understood that we

ដោយសារមូលហេតុទាំងនេះហើយ កម្ពុជាយល់ថា ការចរចាររបស់យើងលើវិស័យសេវាកម្មអាចធ្វើអោយប្រសើរថែមទៀតនូវយុទ្ធសាស្រ្តទូទៅរបស់យើងក្នុងការកែលំអបរិយាកាសពាណិជ្ជកម្មនៅកម្ពុជា។ យើងបានដឹងថា សេចក្តីសំរេចរបស់អគ្គក្រុមប្រឹក្សាអង្គការពាណិជ្ជកម្មពិភពលោក (សូមអានខាងលើ) អំពាវនាវអោយប្រទេសជាសមាជិកកំរិតនូវទំហំនៃការចរចាលើវិស័យសេវាកម្ម ។ ទោះជាយ៉ាងណាក៏ដោយ ជាជាងប្រឹងប្រែងកំរិតលើការសន្យារបស់យើងអោយនៅត្រឹមកំរិតទាបបំផុតនោះ កម្ពុជាជ្រើសយកការចរចាបើកទីផ្សារសេវាកម្មដោយពិនិត្យលើ វិស័យសេវាកម្មជាក់ស្តែងនីមួយៗ ហើយដែលការធ្វើសេរីភាវូបនីយកម្មលើវិស័យសេវាកម្មទាំងនោះ នឹងជួយជំរុញអោយកម្ពុជាឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍ទូលំទូលាយជាង ហើយកម្ពុជាបានរៀបចំចរចា និងទទួលយកការសន្យាលើវិស័យសេវាកម្ម តាមបែបនោះ ។

**៥-<u>ការរក្សាទុកជំរើសគោលនយោបាយ និងភាពអាចប្រែប្រួលបានចំពោះវិស័យ</u>** **<u>កសិកម្ម</u>:** ការបើកចំហរទីផ្សារ (ចំណុចទី១ខាងលើ) និងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគទុន (ចំណុចទី៤ខាងលើ) នឹងផ្តល់ផលប្រយោជន៍ដល់វិស័យកសិកម្ម ក៏ដូចជាវិស័យសេវាកម្ម និងផលិតកម្ម ។ ទោះជាយ៉ាងណាក៏ដោយ យើងដឹងថា មានវិធានពិសេសខ្លះនៃវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលអនុញ្ញាតិអោយរដ្ឋាភិបាលអាចផ្តល់ការឧបត្ថម្ភធនដល់វិស័យកសិកម្មបាន ។ វិធានទាំងនេះត្រូវបានធ្វើឡើង ដើម្បីធានាថា វិធានការគាំទ្រដែលធ្វើអោយប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្ម មិនត្រូវបានអនុញ្ញាត្តិអោយយកមកប្រើប្រាស់ឬបង្កើនសកម្មភាពទេ ហើយវិធានការកំពុងអនុវត្តបច្ចុប្បន្ន ដែលប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មត្រូវកាត់បន្ថយជាបណ្តើរៗអោយនៅចំនួនតិចបំផុត ។ យើងជឿជាក់ថា កម្ពុជាគឺជាប្រទេសដែលអាចប្រកួតប្រជែងបានរឺមានសក្តានុពលក្នុងការប្រកួតប្រជែងលើផលិតផលកសិកម្មជាច្រើនមុខ ។ វិធានដែលតំរូវអោយកាត់បន្ថយការឧបត្ថម្ភធន ផ្តល់ដោយបណ្តាប្រទេសដទៃដល់អ្នកផលិតអាចផ្តល់ជាផលប្រយោជន៍ ។ ទោះបីយ៉ាងណាក៏ដោយ ដូចបានរៀបរាប់ជូន

would need to maintain minimal, but adequate, tariff protection of agricultural products, and retain the right to provide support to domestic producers that genuinely assists them in becoming more competitive. Achieving these ends was an important element of our accession strategy.

6. **Securing LDC benefits with regard to public health.** At its Ministerial Conference in Doha in 2001, WTO adopted a Declaration granting Least Developed Countries certain special privileges as regards WTO requirements for the protection of patents on pharmaceutical products. The objective of the Declaration, and subsequent implementing decisions, was to allow LDCs to have access to cheap drug products, including the right to import cheap pharmaceuticals. This provision is particularly important for Cambodia, since we have difficult public health issues as regards HIV AIDS, tuberculosis, malaria, and other major diseases. At the same time, we are dependent on imports of drugs to fight these diseases, and the financial resources available are limited. It is therefore of great importance that we should have access to medicines at the lowest possible prices. Ensuring that the WTO Declaration applied fully to Cambodia was thus an important objective of our negotiations.

These, then, were the pillars of the negotiating strategy that guided us throughout our discussions with WTO Members.

ដល់អ្នកផលិតអាចផ្តល់ជាផលប្រយោជន៍ ។ ទោះបីយ៉ាងណាក៏ដោយ ដូចបានរៀបរាប់ជូនខាងលើយើងយល់ថា កម្ពុជាត្រូវរក្សាទុកការការពារតាមរយៈពន្ធគយអោយនៅកំរិតទាបបំផុត ប៉ុន្តែគ្រប់គ្រាន់សំរាប់ការការពារផលិតផលកសិកម្ម និង រក្សាសិទ្ធិក្នុងការផ្តល់ការឧបត្ថម្ភធនចំពោះអ្នកផលិតក្នុងស្រុក ដើម្បីជួយអោយពួកគេអោយអាចប្រកួតប្រជែងបានជាងមុន ។ ការសំរេចបានដូចនេះ គឺជាកត្តាដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់យើងក្នុងការចរចាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

**៦-ការធានាអោយបាននូវផលប្រយោជន៍ជាប្រទេសក្រីក្រចំពោះសុខភាពសាធារណៈ**

នាសន្និសីទថ្នាក់រដ្ឋមន្ត្រី នៅទីក្រុងដូហា នៅឆ្នាំ២០០១ អង្គការពាណិជ្ជកម្មពិភពលោកបានអនុម័តលើសេចក្តីប្រកាសមួយ ដែលផ្តល់អោយប្រទេសក្រីក្រនូវសិទ្ធិពិសេសមួយចំនួនទាក់ទិននឹងលក្ខខ័ណ្ឌតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក សំរាប់ការពារប្រកាសនីយប័ត្រតក្កកម្មលើផលិតផលឱសថ ។ គោលបំណងនៃសេចក្តីប្រកាសនេះ និងសេចក្តីសំរេចផ្សេងៗសំរាប់ការអនុវត្តន៍ជាបន្តបន្ទាប់ គឺដើម្បីអនុញ្ញាតអោយបណ្តាប្រទេសក្រីក្រអាចទទួលបាននូវសិទ្ធិក្នុងការផលិតថ្នាំពេទ្យដែលអាចមានតំលៃថោក រួមទាំងសិទ្ធិក្នុងការនាំចូល ផលិតផលឱសថដែលមានតំលៃថោកផងដែរ ។ ប្រការចែងនេះមានសារៈសំខាន់ណាស់សំរាប់កម្ពុជា ដោយយើងមានបញ្ហាលំបាក ផ្នែកសុខាភិបាលសាធារណៈ ដូចជា ជម្ងឺហ៊ីវ អេដស៍ របេង អាសន្នរោគ និងជម្ងឺឆ្លងផ្សេងទៀត ។ ជាមួយគ្នានេះ ដែរ យើងពឹងពាក់ទាំងស្រុងលើការនាំចូលថ្នាំពេទ្យដើម្បីប្រឆាំងនឹងជម្ងឺទាំងនោះ ប៉ុន្តែធនធានហិរញ្ញវត្ថុរបស់យើងមានកំរិត ។ ហេតុដូច្នេះវាមានសារៈសំខាន់ខ្លាំងណាស់ ដែលយើងគួរទទួលបានថ្នាំពេទ្យក្នុងតំលៃទាបបំផុតតាមតែអាចធ្វើបាន ។ ការធានាបានថា សេចក្តីប្រកាសរបស់អង្គការពាណិជ្ជកម្មពិភពលោក អាចអនុវត្តបានយ៉ាងពេញលេញចំពោះកម្ពុជានោះ គឺជាគោលបំណងយ៉ាងសំខាន់ នៃការចរចារបស់យើង ។

កត្តាទាំងអស់នេះហើយ គឺជាការពិចារណាចំបង ដែលយើងពិចារណាក្នុងការចរចាជាមួយសមាជិកនានា នៃអង្គការពាណិជ្ជកម្មពិភពលោក ។

# The Negotiations

## Setting the Process in Motion

Cambodia first applied for membership in WTO in 1994. It was not until 1997, however, that we were in a position to undertake the very complex tasks required to set the process of accession in motion.

The first step in the accession process is for the candidate country to prepare a "Memorandum on the Trade Regime". This memorandum is designed to inform the Members of WTO of all the laws, regulations and government decisions and policies affecting trade. The memorandum must be drawn up following an outline established by WTO, and covering all the items included in the outline. The main topics that needed to be covered by the memorandum included:

- monetary and fiscal policy;
- state ownership and privatization policies;
- pricing and competition policies;
- rules regarding the right to trade;
- customs procedures, in particular customs valuation procedures;
- the application of internal taxes to imports;
